# របាយការណ៍ អភិវឌ្ឍន៍ប្រចាំឆ្នាំ

World Vision

កម្ពុជា

## ២០០៥



# ទស្សនវិស័យ
## របស់យើង

គឺចង់ឃើញកុមារគ្រប់រូប មានជីវិតពេញបរិបូរណ៌

# សេចក្ដីអធិស្ឋាន
## របស់យើង

សូមអោយទឹកចិត្តមនុស្សគ្រប់រូប មានឆន្ទៈដើម្បីសំរេចបំណងនេះ

# សេចក្ដីថ្លែងការណ៍
## បេសកកម្ម

អង្គការទស្សនៈពិភពលោក គឺជាដៃគូអន្តរជាតិមួយ
នៃគ្រីស្ទបរិស័ទ ដែលមានបេសកកម្មដើរតាមព្រះអម្ចាស់
ព្រះយេស៊ូវគ្រីស្ទ ជាព្រះសង្គ្រោះ ដោយធ្វើការ
ជាមួយជនក្រីក្រ និងជនដែលរងការគាបសង្កត់ដើម្បីបង្កើត
អោយមានការផ្លាស់ប្រែដល់មនុស្សជាតិ ស្វែងរកភាពយុត្តិធម៌
និងធ្វើបន្ទាល់ពីដំណឹងល្អនៃនគរព្រះ ។

# សារលិខិត
# របស់នាយិកា
# ប្រចាំប្រទេស

អង្គការទស្សនៈពិភពលោកកម្ពុជាមានការរីកចំរើនធំឡើងៗគួរឱ្យកត់សំគាល់ក្នុងកំឡុងពេលប្រាំឆ្នាំកន្លងមក ហើយមានភាពចាស់ទុំជាអង្គការមួយដែលធ្វើការប្តូរផ្តាច់ដើម្បីកែប្រែជីវិតរបស់ប្រជាជនកម្ពុជាអោយមានភាពប្រសើរឡើង និងដើម្បីបញ្ជាក់ពីសក្ខីភាពនៃសេចក្តីស្រឡាញ់របស់ព្រះជាអម្ចាស់។

យើងសំឡឹងទៅកាន់ឆ្នាំ ២00៥ វិញ ដោយអំណរព្រះគុណយ៉ាងជ្រាលជ្រៅចំពោះព្រះជាអម្ចាស់ ដែលបានផ្តល់ដល់យើងដោយសេចក្តីសប្បុរសនូវសំភារៈ ភស្តុភារ និងធនធានមនុស្ស ដើម្បីអាចធ្វើឱ្យយើងកែប្រែសហគមន៏គោលដៅរបស់យើងបាន។

យុទ្ធសាស្ត្រជាតិរបស់យើងខ្ញុំសំរាប់រយៈពេលប្រាំឆ្នាំបន្ទាប់ គឺជាអនុផលនៃដំណើរការប្រឹក្សាយោបល់ និងឆ្លុះបញ្ចាំងយ៉ាងទូលំទូលាយនូវការរៀបចំយ៉ាងរហ័ស ដែលមានការចូលរួមពីភាគីពាក់ព័ន្ធក្នុងរយៈពេលមួយឆ្នាំអំពីវប្បធម៌អង្គការ និងទិសដៅរបស់យើងខ្ញុំ ក៏ដូចជាកិច្ចប្រឹក្សាយោបល់ខាងក្រៅជាមួយនឹងភាគីពាក់ព័ន្ធ និងដៃគូរបស់យើងខ្ញុំដែរ។ វាពឹងផ្អែកទៅលើចក្ខុវិស័យសន្តិភាពពីមុនរបស់យើងគឺ យុត្តិធម៌ និងសុខមាលភាពប្រជាជនកម្ពុជា ប៉ុន្តែផ្តោតយ៉ាងច្បាស់លាស់ទៅលើកុមារដែលងាយទទួលការរងគ្រោះ។

នៅក្នុងកំឡុងពេលប្រាំឆ្នាំខាងមុខ យើងនឹងអនុវត្តទិសដៅជាយុទ្ធសាស្ត្រទាំងប្រាំរបស់យើងគឺ យុទ្ធសាស្ត្រសន្តិសុខ ស្បៀងអាហារនិងទឹក យុទ្ធសាស្ត្រអប់រំ យុទ្ធសាស្ត្រសុខភាពនិងអាហាររូបត្ថម្ភ យុទ្ធសាស្ត្រសន្តិភាពនិងយុត្តិធម៌ និងយុទ្ធសាស្ត្រមេរោគអេដស៍ ជំងឺអេដស៍។ យើងក៏បានប្តេជ្ញាផងដែរ ក្នុងការពង្រីកនូវការអភិវឌ្ឍន៏មីក្រូសហគ្រាស តាមរយៈវីសិនហ្វាន់កម្ពុជា ដែលជាស្ថាប័នមីក្រូហិរញ្ញវត្ថុត្រូវបានបង្កើតជាសមាសធាតុរួមនៃការអភិវឌ្ឍន៏សហគមន៏ឱ្យបានកាន់តែធំទូលាយ នៅក្នុងកម្មវិធីអភិវឌ្ឍតំបន់របស់អង្គការទស្សនៈពិភពលោក។

ក្នុងនាមជាដៃគូផ្អែកអភិវឌ្ឍន៏ និងជំនួយសង្គ្រោះគ្រីស្ទបរិស័ទទស្សនៈពិភពលោកកម្ពុជាសូមអះអាងថាការប្រែប្រួលទាំងនេះ គឺបានទទួលមកពីព្រះជាអម្ចាស់ជាជាងបានមកពីអង្គការទស្សនៈពិភពលោក។ ដោយហេតុដូច្នេះហើយ យើងនឹងបន្តធ្វើការងារជាដៃគូជាមួយនឹងព្រះវិហារ អង្គការដែលផ្អែកលើជំនឿ និងអ្នកដឹកនាំសាសនាក្នុងតំបន់ដើម្បីរួមចំណែកក្នុងការផ្លាស់ប្តូរស្មារតី និងសង្គមនៃប្រទេសកម្ពុជា។

ការងារដែលយើងបានកំណត់ថានឹងសំរេចឱ្យបានគឺមានទំហំធំជាងយើងទាំងអស់គ្នា។ ខ្ញុំសូមបញ្ជាក់យ៉ាងខ្លាំងថា យើងនឹងធ្វើការងារឥតឈប់ឈរដើម្បីស្វែងរកភាពជាដៃគូជាមួយរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ស្ថាប័ន សាសនា និងសង្គមដែលកំពុងតែដំណើរការនៅក្នុងប្រទេស។

ជាមួយនឹងក្រុមប្រឹក្សាយោបល់ ក្រុមគ្រប់គ្រង និងដឹកនាំរបស់យើង បុគ្គលិកហាត់ការ និងបុគ្គលិកស្ម័គ្រចិត្តជាង ១000 នាក់ នៅទូទាំងប្រទេស សង្ឃឹម និងទន្ទឹងថានឹងបានធ្វើការ និងសហការជាមួយលោកអ្នកដើម្បីសំរេចឱ្យបាននូវគោលដៅរួមគ្នារបស់យើង និងដើម្បីជាប្រយោជន៏សំរាប់ប្រជាជនកម្ពុជាទាំងអស់ជាពិសេស ដើម្បីឱ្យកុមារមានជីវិតពេញបរិបូរណ៍មានសន្តិភាព និងយុត្តិធម៌។

ដោយក្តីស្មោះស្ម័គ្រអំពីខ្ញុំ



អែស្ទើរ ហាលីម
នាយិកាប្រចាំប្រទេស

# លទ្ធផល សំរេចបានរបស់កម្មវិធី អភិវឌ្ឍន៍តំបន់



កម្មវិធីអភិវឌ្ឍន៍តំបន់របស់អង្គការទស្សនៈពិភពលោកកម្ពុជា (ADPs) ដំណើរការនៅក្នុងស្រុកចំនួន ២៧ ក្នុងខេត្ត ៧ និងថ្នាក់ក្រុង ២ នៅក្នុងទីក្រុងភ្នំពេញ។ ADPs គឺជាយុទ្ធសាស្ត្ររួមមួយនៅក្នុងការបំផ្លាស់ប្រែប្រជាជន និងសហគមន៏តាមរយៈភាពជាដៃគូយូរអង្វែងជាមួយនឹងអ្នកភូមិដើម្បីលើកកំពស់ជីវភាពរស់នៅដល់កុមារ និងគ្រួសាររបស់ពួកគេ។

នៅក្នុងឆ្នាំ ២០០៥ តំបន់អនុវត្តគំរោងរបស់អង្គការទស្សនៈពិភពលោកកម្ពុជា បានជួយកសាងផ្លូវក្នុងជនបទប្រវែងជាង ៥១៩ គីឡូម៉ែត្រ ស្ពានបី និងប្រឡាយជិត ៤០០០ ម៉ែត្រ។ យើងបានជួយធ្វើឱ្យមានដំណើរការឡើងវិញនូវទ្វារទឹកចំនួន ៤ និងផ្តល់នូវអណ្តូងស្នប់ដៃ និងអណ្តូងជីកចំនួន ៩៣៨ ដើម្បីជាជំនួយដល់ការងារកសិកម្មរបស់សហគមន៏។ ស្រូវជាង ១០៥ តោន ត្រូវបានប្រគល់ជូនដល់ធនាគារស្រូវរបស់ភូមិ។ ADPs បានផ្តល់ជូនធនាគារសត្វផងដែរនូវគោចំនួន ៩៧២ ក្បាល ដែលត្រូវបែងចែកជូន ៣៥១ ភូមិ។ ការបណ្តុះបណ្តាលក្នុងផ្នែកកសិកម្ម និងចិញ្ចឹមសត្វ ត្រូវបានធ្វើឡើងក្នុងគោលបំណងជួយសហគមន៏អោយចេះថែរក្សាទ្រព្យរបស់ពួកគេ។

យើងធ្វើការជាដៃគូជាមួយនឹងមណ្ឌលសុខភាពដោយធានានូវការចាក់ថ្នាំបង្ការដល់កុមារជាង ២០.០០០ នាក់ ។ យើងបានកសាងមណ្ឌលសុខភាពថ្មីជាច្រើន និងផ្តល់បង្គន់អនាម័យចំនួន ២០០០ ដល់សហគមន៏។ យើងបណ្តុះបណ្តាលភ្នាក់ងារសុខភាព ភូមិស្ម័គ្រចិត្តចំនួន ៤៨៦៥ នាក់ ដើម្បីជួយដល់សហគមន៏។



# អ្នកទំនុកបំរុង ធ្វើអោយមានការផ្លាស់ប្តូរ

នៅក្នុងឆ្នាំ ២០០៥ កុមារជាង ៥០.០០០ នាក់ ត្រូវបានជួយទំនុកបំរុងនៅក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ចំនួន ២៤ ទូទាំងប្រទេសកម្ពុជា។ ប្រយោជន៍នៃការជួយឧបត្ថម្ភដល់កុមារពង្រីកនូវឥទ្ធិពលយ៉ាងធំធេង មិនត្រឹមតែសំរាប់កុមារម្នាក់ៗ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំរាប់គ្រួសារ និងសហគមន៍របស់ពួកគេទាំងមូលទៀតផង។

កុមារី យ៉ុង ចន្ទី ស្ទើរតែនឹងបោះបង់ចោលការសិក្សា ហើយទៅធ្វើការងាររោងចក្រដើម្បីជួយដល់ម្តាយរបស់នាងទៅហើយ ប៉ុន្តែសូមអរគុណដល់កម្មវិធីផ្តល់ជំនួយឧបត្ថម្ភ ចន្ទីឥឡូវនេះបានក្លាយជាសិស្សឆ្នើមម្នាក់ក្នុងចំណោមសិស្សឆ្នើមទាំងដប់នៅក្នុងថ្នាក់ទី ១១។

*"ខ្ញុំកើតនៅក្នុងគ្រួសារក្រីក្រមួយក្នុងខេត្តកំពង់ស្ពឺ។ យើងរស់នៅក្នុងកូនផ្ទះឈើតូចមួយ ឪពុកម្តាយរបស់ខ្ញុំទាំងពីរនាក់ជាប់រវល់ជាមួយនឹងការងារស្រែចំការ និងការងារបន្ថែមទៀតខ្លាំងណាស់។ ដូច្នេះខ្ញុំត្រូវជួយពួកគាត់ធ្វើការងារផ្ទះ។*

*នៅពេលខ្ញុំពេញវ័យ ខ្ញុំមានបំណងចង់ក្លាយខ្លួនជាភ្នាក់ងារអភិវឌ្ឍន៍សហគមន៍។ ខ្ញុំគិតថា ខ្ញុំយល់ និងដឹងច្រើនអំពីស្ថានភាពប្រជាជនរស់នៅក្នុងភាពក្រីក្រ ពីព្រោះកាលពីមុនខ្ញុំក៏មានបទពិសោធន៍ឆ្លងកាត់ភាពក្រីក្រនេះដែរ។ ខ្ញុំមានបំណងជួយសហគមន៍របស់ខ្ញុំ គ្រួសាររបស់ខ្ញុំ និងជួយឧបត្ថម្ភប្អូនស្រីរបស់ខ្ញុំឱ្យនាងបានរៀនសូត្របន្តទៀត។ ខ្ញុំចង់នាំមកនូវស្នាមញញឹម និងក្តីសង្ឃឹមដល់កុមារៗនៅក្នុងសហគមន៍របស់ខ្ញុំ។*

*អង្គការទស្សនៈពិភពលោកបានផ្តល់ឱកាសដល់រូបខ្ញុំដែលជាកុមារក្រីក្រម្នាក់ ដែលអាចនឹងមិនមានលទ្ធភាពទទួលបានការអប់រំផង បើគ្មានជំនួយ។ សូមថ្លែងអំណរគុណចំពោះសប្បុរសជន អ្នកទំនុកបំរុងកុមាររបស់អង្គការទស្សនៈពិភពលោក សំរាប់ជំនួយឧបត្ថម្ភដែលលោកអ្នកបានផ្តល់ចំពោះរូបខ្ញុំ គ្រួសាររបស់ខ្ញុំ និងសហគមន៍របស់ខ្ញុំ។"*

# ការផ្តល់អំណាចដល់កុមារ



គំរោងទប់ស្កាត់កុមាររងាយរងគ្រោះ (CHRPP) ផ្តល់សិទ្ធិអំណាចដល់កុមារដើម្បីឱ្យពួកគេអាចការពារខ្លួនដោយខ្លួនឯង ពីអំពើហិង្សា ការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ តាមរយៈការអប់រំតាមសហគមន៍។ CHRPP បានដំណើរការក្លឹបកុមារនៅក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់ ដែលមានស្រាប់ដើម្បីផ្តល់ដល់កុមារឱ្យទទួលយកតួនាទីវិជ្ជមាន និងបណ្តុះបណ្តាលពួកគេអំពីសិទ្ធិកុមារដើម្បីទប់ស្កាត់នូវការជួញដូរ និងកេងប្រវ័ញ្ចលើកំលាំងពលកម្មកុមារ។

គំរោងផ្តល់ក្តីសង្ឃឹម BHP ធ្វើការគាំទ្រដោយផ្តោតលើការអប់រំកំរិតខ្ពស់សំរាប់យុវជនពិការ។ BHP ធ្វើការដើម្បីផ្តល់ការគាំទ្រ និងបញ្ជ្រាបយុវជនពិការអោយទទួលបានការអប់រំដ៏ពេញលេញ និងបន្តទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈផ្សេងៗ។ បច្ចុប្បន្ននេះ មានសិស្សពិការ ១៣០ នាក់ កំពុងទទួលការគាំពារតាមរយៈការផ្តល់អាហារូបករណ៍។

គំរោងបញ្ជ្រាបបញ្ហាពិការភាព (DMP) ផ្តោតលើការធ្វើឱ្យកុមារពិការបានចូលរួមក្នុងសកម្មភាពរបស់កម្មវិធីអភិវឌ្ឍន៍តំបន់។ គំរោងមានបំណងផ្លាស់ប្តូរគំនិតមើលស្រាលជនពិការ និងដើម្បីបង្ហាញដល់សមាជិកក្នុងសហគមន៍នៅក្នុងកម្មវិធីអភិវឌ្ឍន៍តំបន់របស់យើងថា ជនពិការអាចចូលរួមចំណែកជាវិភាគទានដល់ជីវភាពរបស់ភូមិស្រុកបាន។ អង្គការទស្សនៈពិភពលោកធ្វើការផងដែរជាមួយនឹងសាលារដ្ឋ និងគ្លីនិកតាមតំបន់អភិវឌ្ឍន៍របស់ខ្លួន ដើម្បីអាចឱ្យកុមារពិការទទួលបានសេវាកម្មទាំងនេះដោយងាយស្រួល។



# ការឈោងអោយ ដល់កុមារ អនាថា

បុគ្គលិកចុះផ្សព្វផ្សាយ និងអ្នកអប់រំមិត្ត របស់មជ្ឈមណ្ឌលកុមារទំពាំងស្នងឬស្សី (BSCC) បានធ្វើការរៀងរាល់សប្តាហ៍ដើម្បីបង្កើតទំនាក់ទំនងជាមួយនឹងកុមារអនាថាតាមដងផ្លូវ។ ក្រុមការងារបានចែកចាយព័ត៌មានអំពីសេវាកម្មដែលកុមារអាចទទួលបាន។ ពួកគេក៏បានផ្តល់ដំបូន្មាន និងបញ្ជូនកុមារទាំងនោះទៅកាន់ BSCC ដើម្បីទទួលបានសេវាកម្មបន្ថែមផងដែរ។ នៅក្នុងឆ្នាំ ២00៥ ក្រុមការងារបានបញ្ជូនកុមារចំនួន ២៣ នាក់ទៅកាន់ BSCC។

កុមារដែលរស់នៅក្នុង BSCC បានទទួលការអប់រំអនាម័យមូលដ្ឋាន ការអប់រំសុខភាព និងការការពារពីជំងឺឆ្លងផ្សេងៗ។ មជ្ឈមណ្ឌល BSCC ក៏បានផ្តល់ផងដែរនូវការប្រឹក្សាយោបល់ផ្នែកចិត្តសាស្ត្រ សកម្មភាពកំសាន្ត បំណិនជីវិត និងបណ្តុះបណ្តាលអក្ខរកម្មផងដែរ។ កុមារដែលមានអាយុគ្រប់ចូលរៀនថ្នាក់បឋមសិក្សា ត្រូវបានជួយឧបត្ថម្ភឱ្យចូលរៀនសាលាផ្លូវការ។ សព្វថ្ងៃនេះសិស្សចំនួន ២១ នាក់ មកពីមជ្ឈមណ្ឌល BSCC កំពុងចូលរៀននៅក្នុងសាលាជាស្ថាពរ។

បន្ថែមលើចំណីអាហារមូលដ្ឋានដែលបានចែកចាយដល់កុមារអនាថាកំពុងតែរស់នៅ និងធ្វើការនៅតាមដងវិថី ក្រុមការងារចុះផ្ទាល់បានផ្តល់ជំនួយសង្គ្រោះបឋម និងជំនួយសុខភាពដែលចាំបាច់ខ្លាំងដល់កុមារ និងគ្រួសារក្រីក្រ។ អ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ត្រូវបានផ្តល់ការឧបត្ថម្ភថ្លៃធ្វើដំណើរទៅកាន់មន្ទីរពេទ្យរដ្ឋ។

# ការបង្ហាញរបាយការណ៍ ស្តីពីការរំលោភ បំពានលើកុមារ



អង្គការទស្សនៈពិភពលោកកម្ពុជាចូលរួមជាមួយដៃគូក្នុងការសិក្សាធ្វើរបាយការណ៍ស្តីពីការ "បញ្ឈប់អំពើហិង្សាលើពួកខ្ញុំ!"។ ការសិក្សានេះគឺមានបំណងស្តាប់នូវការយល់ឃើញផ្ទាល់របស់កុមារ និងបន្តិះរកគ្រប់មធ្យោបាយសំដៅធ្វើការដោះស្រាយបញ្ហាអំពើហិង្សាលើកុមារៈ ការរំលោភបំពានផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ និងការដាក់ទណ្ឌកម្មលើរូបរាងកាយ។

កុមារចំនួន ១,៣១៤ នាក់ មានអាយុពី ១២ ទៅ ១៥ ឆ្នាំ ដែលត្រូវបានអង្កេតបានឱ្យដឹងថាមានក្មេងស្រី និងប្រុសក្នុងភាគរយខ្ពស់យ៉ាងខ្លាំង គឺក្មេងស្រីដែលបានផ្តល់ចំលើយ ៦៣.៥% និងក្មេងប្រុសដែលបានផ្តល់ចំលើយ ៦៤.0% មានការយល់ដឹងពីកុមារដែលត្រូវគេចាប់រំលោភ។ ក្មេងប្រុស ៥0% និងក្មេងស្រី ៣៦.៤% ដែលជាចំនួនគួរឱ្យភ្ញាក់ផ្អើលបានសារភាពថាត្រូវបានវាយដំដោយឪពុកម្តាយ។ អំពើហិង្សានៅតែបន្តនៅក្នុងស្ថាប័នសាធារណៈ ដោយក្មេងស្រី ២៤.១% និងក្មេងប្រុស ៣៤.៧% បាននិយាយថា ពួកគេត្រូវបានវាយដំដោយលោកគ្រូអ្នកគ្រូ ។ វិធីមួយចំនួនដែលធ្លាប់បានប្រើប្រាស់ដើម្បី "ដាក់វិន័យ" ដល់សិស្សត្រូវបានអត្ថាធិប្បាយនៅក្នុងការសិក្សាក្រុមគោលដៅថាជារឿងដែលគួរឱ្យបារម្ភ។

របាយការណ៍នេះជាជំនួយយ៉ាងសំខាន់ដើម្បីនាំផ្លូវគំរោងអនាគតរបស់អង្គការទស្សនៈពិភពលោក ក្នុងបំណងបង្ហាញចេញអោយកាន់តែទូលាយដល់ប្រជាជន និងសហគមន៍ អំពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ ក៏ដូចជាអំពើហិង្សាក្នុងសហគមន៍ទាំងមូល។ យោងទៅតាមលទ្ធផលនៃការស្រាវជ្រាវការផ្តួចផ្តើមទាំងឡាយ បានស្ថាបនាសន្តិភាពយ៉ាងសកម្ម និងខិតខំស្វែងរកយុត្តិធម៌ជូនកុមារជាច្រើនដែលត្រូវបានគេរំលោភបំពានសិទ្ធិ ឥឡូវនេះឃើញថា មានភាពប្រសើរឡើងជាលំដាប់។



# ការជួយស្តារ ផ្លូវចិត្តកុមារ

មជ្ឈមណ្ឌលស្តារផ្លូវចិត្ត (TRC) ថ្មីៗនេះ បានជួយឧបត្ថម្ភដល់ក្មេងស្រី ១៤០ នាក់ ដែលទទួលរងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទ។ ក្មេងស្រីចំនួន ៨៨ នាក់ ត្រូវបានទទួលចូលក្នុងមជ្ឈមណ្ឌលក្នុងឆ្នាំ ២០០៥។

ក្មេងស្រីដែលត្រូវបានគេជួញដូរ និង/ឬ រំលោភបំពានផ្លូវភេទ ត្រូវបានទទួលការមើលថែជារួម។ សកម្មភាពនៅឯ TRC រួមមាន: ការប្រឹក្សាយោបល់ផ្នែកចិត្តសាស្ត្រ ការបណ្តុះបណ្តាលជំនាញ និងការធ្វើសមាហរណកម្មទៅក្នុងសហគមន៍វិញ។ នៅពេលចាកចេញពី TRC វិញ យុវតីជាច្រើនមានជំនាញវិជ្ជាជីវៈជាប់នៅនឹងខ្លួន។ មជ្ឈមណ្ឌលបានផ្តល់ផងដែរនូវបរិក្ខាដែលត្រូវការដើម្បីជួយបង្កើតរបររកស៊ីចាំបាច់សំរាប់ក្មេងស្រីទាំងនោះ និងគ្រួសាររបស់ពួកគេ។

បុគ្គលិក TRC បានអនុវត្តសកម្មភាពចុះផ្សព្វផ្សាយតាមសហគមន៍។ បុគ្គលិកបានធ្វើដំណើរទៅកាន់ភូមិនានាដើម្បីលើកកំពស់ការយល់ដឹងអំពីការជួញដូរកុមារ ការកេងប្រវ័ញ្ចផ្លូវភេទ សិទ្ធិកុមារ ការឆ្លងជំងឺអេដស៍ និងអំពើហិង្សាក្នុងគ្រួសារ។

មជ្ឈមណ្ឌល TRC ធ្វើការសហការណ៍ជាមួយនឹងក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន និងយុវនីតិសម្បទា។ ដៃគូផ្សេងទៀតរួមមាន អង្គការសិទ្ធិមនុស្ស អាជ្ញាធរមូលដ្ឋាន និងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត។

# ការសំអាតផ្ទៃដីអោយមានសុវត្ថិភាព និងអំណោយផលដល់កសិកម្ម




នៅឆ្នាំ ២០០៥ ជាពេលបញ្ចប់នៃកម្មវិធី IMAP ។ កម្មវិធីនេះបានចាប់ផ្តើមកាលពីថ្ងៃទី ១ខែមេសា ឆ្នាំ២០០៣ ដោយចូលរួមជាដៃគូជាមួយនឹងក្រុមប្រឹក្សាយោបល់អំពីគ្រាប់មីន និងអង្គភាពរៀបចំផែនការកំចាត់មីនរបស់រដ្ឋាភិបាលកម្ពុជា អង្គការទស្សនៈពិភពលោកអាចជួយពង្រីកដីទំនេរសំរាប់ប្រជាជនក្រីក្រ។ ក្រុមកំចាត់មីនទាំងពីរបានធ្វើការបោសសំអាតលើផ្ទៃដី ៤៤៩,៨៦៣ ម៉ែត្រក្រឡា នៅក្នុងខេត្តបាត់ដំបង និងខេត្តព្រះវិហារ និងបានរកឃើញគ្រាប់មីនប្រឆាំងសត្រូវចំនួន ២០៥ គ្រាប់ គ្រាប់មិនទាន់ផ្ទុះប្រភេទ ៤៤៦ UXOx គ្រាប់មីនប្រឆាំងរថក្រោះ ៩ គ្រាប់ និងអំបែងកំទេចកំទីចំនួន ១,៦៦៦,៨៣៦។

បុគ្គលិកបានបើកវគ្គយល់ដឹងពីបញ្ហាគ្រាប់មីនយ៉ាងតិច ១២០ ដង នៅតាមភូមិក្នុងខេត្តទាំងពីរ។ នៅក្នុងវគ្គសិក្សាទាំងនេះ មានអ្នកចូលរួមចំនួន ៨០១៣ នាក់ រាប់បញ្ចូលទាំងស្ត្រីចំនួន ៣,៩៥៣ នាក់ផង។ អ្នកចូលរួមចំនួន ៧០% មកពីខេត្តព្រះវិហារ និងឡើងដល់ ៩០% មកពីខេត្តបាត់ដំបង បានសំដែងឱ្យឃើញពីការយល់ដឹងពីរបៀបការពារគ្រាប់មីនកុំឱ្យបង្កគ្រោះថ្នាក់។ សមាជិកសហគមន៏ទទួលបានប្រយោជន៏ពីការបណ្តុះបណ្តាលអំពីការដាំដុះដំណាំឆ្លាស់ប្រភេទផងដែរ។ ដំណាំដែលដាំដុះដោយគ្រួសារនៅលើដីសំអាតមីនរួចរាល់មាន: សណ្តែកបាយ សណ្តែកសៀង ត្រាវ ដំឡូងជ្វា ក្តួច និង ស្លឹកគ្រៃ។ កម្មវិធីនេះបានបង្កើតគំរូសួនដំណាំគ្រួសារ និងបង្ហាញពីការពិសោធន៏លើដំណាំដល់សហគមន៏ផងដែរ។



# ការស្ថាបនាសហគមន៍អោយកាន់តែមានតម្លាភាព

អង្គការទស្សនៈពិភពលោកកម្ពុជាបង្កើតដៃគូជាមួយបណ្តាព្រះវិហារក្នុងតំបន់ចំនួន ១៧ សំដៅផ្តល់ការគាំទ្រដល់ក្រុមវឌ្ឍនៈដែលមានចំនួន ៩៣ ក្រុម ក្រោមគំរោងអភិវឌ្ឍន៍តំបន់ក្នុងស្រុកកំពង់ត្រឡាច។ ជារួមក្រុមវឌ្ឍនៈមានការចូលរួមពីប្រជាជនចំនួន ៥៧៤ គ្រួសារ ដែលមានសមាជិកចំនួន ១,៣៣២ នាក់។

សកម្មភាពនានារបស់ក្រុមវឌ្ឍនៈ គឺប្រារព្ធថ្ងៃបុណ្យឈប់សំរាករួមគ្នា ធ្វើការសិក្សារៀនសូត្រអំពីការថែទាំសុខភាព និងអាហាររូបត្ថម្ភ រៀនសូត្រពីមេរោគអេដស៍និងជំងឺអេដស៍ ព្រមទាំងផ្តល់ការគាំទ្រខាងផ្នែកសេដ្ឋកិច្ចទៅវិញទៅមក។ នៅឆ្នាំ ២០០៥ ការកសាងដៃគូរបស់ស្រុកកំពង់ត្រឡាចជាមួយនឹងព្រះវិហារជាច្រើនបានផ្តល់នូវការគាំទ្រខាងព្រលឹងវិញ្ញាណដល់សមាជិកសហគមន៍ដែលមានមេរោគអេដស៍និងជំងឺអេដស៍ ក៏ដូចជាក្រុមគ្រួសាររបស់ពួកគេផងដែរ។

ក្នុងកិច្ចគាំទ្រលើកកំពស់ស្មារតីរបស់សហគមន៍ និងភាពជាដៃគូដើម្បីសុខភាពរាងកាយនិងស្មារតី កម្មវិធីជាដៃគូបានផ្តល់ជាវគ្គបណ្តុះបណ្តាលអំពីការថែទាំសុខភាព ព្រមទាំងធ្វើការចែកចាយសៀវភៅនៅក្នុងអង្គសិក្ខាសាលានានា។ នៅក្នុងការបណ្តុះបណ្តាលទាំងនោះ រួមមានអ្នកដឹកនាំគ្រីស្តបរិស័ទដែលមកពីបណ្តាព្រះវិហារចំនួន ៧៥ បើកសន្និសីទ ២ លើក សំរាប់អ្នកដឹកនាំក្រុមយុវជនចំនួន ៦០ នាក់ និងមានប្រធានក្រុមកុមារចំនួន ៣០៧ នាក់ បានចូលរួមនៅក្នុងការបណ្តុះបណ្តាលអំពីសិទ្ធិកុមារ។

កម្មវិធីជាដៃគូក៏បានជួយឧបត្ថម្ភដល់ពិធីបុណ្យណូអែលផងដែរ ដែលមានការចូលរួមសប្បាយរីករាយពីកុមារចំនួន ៥,៣៦០ នាក់។ មិនត្រឹមតែប៉ុណ្ណោះ កម្មវិធីនេះក៏បានធ្វើការចែកចាយឯកសណ្ឋានសិស្សសាលាចំនួន ៣៥០ កំផ្លេ និងសៀវភៅអានចំនួន ១,៤៥០ ក្បាល។



# វីសិនហ្វាន់កម្ពុជា ធ្វើអោយជីវភាពរបស់ ប្រជាជនកាន់តែ ប្រសើរឡើង តាមរយៈ សេវាផ្ដល់ប្រាក់កម្ចី

ចាប់តាំងពីបានចុះបញ្ជីជាក្រុមហ៊ុនពាណិជ្ជកម្មមួយដាច់ដោយឡែកកាលពីឆ្នាំ ២០០៣ ក្រោមការគ្រប់គ្រងរបស់អង្គការទស្សនៈពិភពលោក វីសិនហ្វាន់កម្ពុជាបានបន្តពង្រីកយ៉ាងឆាប់រហ័សនូវសេវាកម្មផ្ដល់ប្រាក់កម្ចីខ្នាតតូចដល់ប្រជាជនក្រីក្រ។ នៅក្នុងឆ្នាំ ២០០៥ វីសិនហ្វាន់ (VFC) បានពង្រីកនូវប្រតិបត្តិការរបស់ខ្លួនកាន់តែធំជាងមុនថែមទៀត ដោយបានផ្ដល់សេវាកម្មជូនដល់អតិថិជនជាង ២៥,០០០ នាក់ (កើនឡើង ២៥.៦% ធៀបនឹងឆ្នាំ ២០០៤) ដែលក្នុងនោះប្រាក់កម្ចីមិនទាន់សងមានចំនួន ៣.៤ លានដុល្លារអាមេរិក (កើនឡើង ១២០% ធៀបនឹងឆ្នាំ ២០០៤) រហូតបានក្លាយជាអ្នកផ្ដល់សេវាកម្មមីក្រូហិរញ្ញវត្ថុមួយធំជាងគេលំដាប់ថ្នាក់លេខ ៤ នៅក្នុងប្រទេសកម្ពុជា ព្រមទាំងបានការទទួលស្គាល់ពី CGAP ចំពោះតម្លាភាពខាងហិរញ្ញវត្ថុរបស់ខ្លួន។ ឆ្នាំ ២០០៥ ជាឆ្នាំសមិទ្ធិផលរបស់ VFC ដែលសំរេចបាននូវស្វ័យនិរន្តរភាព ដូច្នេះហើយរាល់ការប្រាក់ដែលប្រមែប្រមូលបានពីប្រាក់កម្ចីដែលមិនទាន់សងគឺអាចជួយឧបត្ថម្ភបានគ្រប់គ្រាន់ទៅលើការចំណាយប្រតិបត្តិការ។

ក្រុមហ៊ុនវីសិនហ្វាន់កម្ពុជា (VFC) ខិតខំស្វះស្វែងជួយដល់អ្នកប្រកបរបររកស៊ីក្រីក្រដើម្បីអាចអោយពួកគេចាប់ផ្ដើមប្រកបអាជីវកម្មដោយខ្លួនឯង។ ដោយផ្ដោតលើការធ្វើជាដៃគូជាមួយនឹងគ្រួសារក្រីក្រដែលធ្វើការដើម្បីទទួលបាននូវជីវភាពមួយដែលមានសុវត្ថិភាព ជីវភាពដ៏រឹងមាំ និងមានភាពថ្លៃថ្នូរ។ វីសិនហ្វាន់កម្ពុជាបានពង្រីកការងាររបស់ខ្លួនកាន់តែធំឡើង និងលើកសរសើរដល់ព័ន្ធកិច្ចនៃអង្គការទស្សនៈពិភពលោកកម្ពុជា។ សេវាកម្មហិរញ្ញវត្ថុដែលផ្ដល់ជូនតាមរយៈវីសិនហ្វាន់កម្ពុជា បានជួយធ្វើឱ្យសុបិន្តរបស់អ្នកក្រក្លាយជាការពិត។ វីសិនហ្វាន់កម្ពុជាបានផ្ដល់ជូនដល់អ្នកក្រនូវជំរើសហិរញ្ញវត្ថុកាន់តែច្រើនជាងមុនជាមួយនឹងអត្រាការប្រាក់ដ៏សមរម្យ។ តាមរយៈការធ្វើទំនាក់ទំនងការងារជាមួយនឹងវីសិនហ្វាន់កម្ពុជា គ្រួសារជាច្រើនអាចនឹងបង្កើននូវទ្រព្យធនបានច្រើន និងជួយពង្រីងដល់មុខជំនួញខ្នាតតូច

របស់ពួកគេមួយក៏រិតថែមទៀតនោះ។ តាមរយៈកម្មវិធីផ្តល់ប្រាក់កម្ចីរបស់វីសិនហ្វាន់កម្ពុជា សព្វថ្ងៃនេះគ្រួសារក្រីក្រទាំងឡាយ អាចមានលទ្ធភាពផ្គត់ផ្គង់ចំណីអាហារបានគ្រប់គ្រាន់ដល់កូនៗរបស់ពួកគេ អាចសន្សំប្រាក់សំរាប់ពេលមានតំរូវការជាបន្ទាន់ មានលទ្ធភាពគ្រប់គ្រាន់សំរាប់ថែទាំសុខភាពគ្រួសាររបស់ខ្លួន អាចពង្រឹងមុខជំនួញរបស់ពួកគេ អ្វីដែលសំខាន់ជាងគេនោះគឺពួកគេអាចមានលទ្ធភាពបញ្ជូនកូនរបស់ខ្លួនឱ្យចូលសាលាបាន។ ពេលដែលស្ថានភាពហិរញ្ញវត្ថុរបស់ពួកគេមានការរីកលូតលាស់ គ្រួសារទាំងនោះនឹងមានជំរើសកាន់តែច្រើនឡើងរហូតដល់អាចឈានដល់ទីផ្សារតណទានធំជាងនេះក៏មានដែរ។

នៅកំឡុងឆ្នាំ ២០០៥ វីសិនហ្វាន់កម្ពុជាបានធ្វើការកែលំអនូវប្រតិបត្តិការរបស់ខ្លួនដោយអនុវត្តប្រព័ន្ធតាមដានប្រាក់កម្ចីដែលមានឈ្មោះថា eMerge។ បន្ទាប់ពីឆ្លងកាត់ដំណាក់កាលអន្តរកាលបន្តិចម្តងៗ អស់រយៈពេលពីរបីឆ្នាំមក វីសិនហ្វាន់កម្ពុជាក៏បានបញ្ចប់នូវដំណើរការដាក់បញ្ចូលក្រុមថ្នាក់គ្រប់គ្រងរបស់ខ្លួន ឱ្យទៅជាក្រុមក្នុងតំបន់។

ឥឡូវនេះ វីសិនហ្វាន់កម្ពុជាមានសក្តានុពលគ្រប់គ្រាន់សំរាប់ធានានូវនិរន្តរភាពរបស់ស្ថាប័ននេះ ព្រមទាំងមានហេដ្ឋារចនាសម្ព័ន្ធកំលាំងពលកម្មយ៉ាងល្អឥតខ្ចោះ និងមានគោលនយោបាយជាច្រើនដែលគាំទ្រចំពោះកំណើនតំរូវការសេវាកម្មមីក្រូហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា។

វីសិនហ្វាន់កម្ពុជាអបអរសាទរចំពោះជោគជ័យរបស់ខ្លួនដោយការសំរេចបាននូវស្វ័យនិរន្តរភាព និងកំណើនប្រសិទ្ធភាពនៅក្នុងការផ្តល់ស្មារតីខាងមុខជំនួញដល់អតិថិជនរបស់យើង ដើម្បីឱ្យពួកគេមានក្តីសង្ឃឹមដ៏រឹងមាំមួយសំរាប់អនាគតយ៉ាងភ្លឺថ្លាខាងមុខ។





# សកម្មភាពការងារ ក្នុងទិសដៅកាត់បន្ថយការ ឆ្លងមេរោគអេដស៍ និង ជំងឺអេដស៍

កុមារឈ្មោះ សួន ថៃ មានអាយុ ១៤ ឆ្នាំ ដែលជាកុមារកំព្រាដោយសារជំងឺអេដស៍ គឺជាក្មេងម្នាក់ក្នុងចំណោមកុមារកំព្រាដែលងាយរងគ្រោះ (OVCs) ចំនួន ២,២៨១ នាក់ និងបណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ (PLHAs) ចំនួន ១,៩៣៧ នាក់ ដែលត្រូវបានផ្លាស់ប្តូរតាមរយៈការកាត់បន្ថយជំងឺអេដស៍ជាយុទ្ធសាស្ត្រ (STAR) ៤,៥ ដែលជាគំរោងរយៈពេល ៥ ឆ្នាំ ក្រោមការឧបត្ថម្ភមូលនិធិរបស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា (CIDA) និងអង្គការទស្សនៈពិភពលោកកាណាដា។ STAR's ផ្តោតគោលដៅជាពិសេសទៅលើអ្នកបើកបររថយន្តដឹកទំនិញ និងប្រជាជនទូទៅដែលរស់នៅតាមបណ្តោយផ្លូវជាតិលេខ ៤ និង លេខ ៥ ក្នុងព្រះរាជាណាចក្រកម្ពុជា។

គំរោងនេះដែលបានបញ្ចប់កាលពីខែ មីនា ឆ្នាំ ២០០៥ បានអនុវត្តនូវគំនិតផ្តួចផ្តើមមួយចំនួនសំដៅជួយដល់ការកាត់បន្ថយនូវការរីករាលដាលនូវមេរោគអេដស៍និងជំងឺអេដស៍ តាមរយៈការផ្សព្វផ្សាយដល់ប្រជាជនឱ្យយល់ដឹងពីគ្រោះថ្នាក់នៃជំងឺអេដស៍ និងផ្តល់ការគាំទ្រដោយផ្ទាល់ជូនដល់អ្នកដែលផ្ទុកមេរោគអេដស៍រួចហើយ តាមរយៈមិត្តអប់រំមិត្ត ការផ្តល់ប្រឹក្សា និងធ្វើតេស្ត ព្រមទាំងផ្តល់ការគាំទ្រដល់បណ្តាញអ្នករស់នៅជាមួយមេរោគអេដស៍និងជំងឺអេដស៍ ការជំរុញឱ្យមានការផ្សព្វផ្សាយពីការផ្លាស់ប្តូរការប្រព្រឹត្ត (BCC) ការផ្តល់ប្រឹក្សា និងធ្វើតេស្តដោយសម្ងាត់ និងតាមការស្ម័គ្រចិត្ត (VCCT) ការថែទាំតាមផ្ទះ និងសហគមន៍ ព្រមទាំងការកសាងសមត្ថភាព។

គំរោង (STAR) ៤,៥ បានធ្វើឱ្យមានការផ្លាស់ប្តូរជាច្រើននៅក្នុងជីវិត ដូចយ៉ាងកុមារឈ្មោះ ថៃ ដែលឥឡូវនេះកំពុងតែសំឡឹងទៅរកអនាគតមួយប្រកបដោយក្តីសង្ឃឹម។ សិស្សរៀនថ្នាក់ទី ៦ ដ៏ឧស្សាហ៍ព្យាយាមរូបនេះបាននិយាយថា "ខ្ញុំចង់ធ្វើជាគ្រូបង្រៀនម្នាក់ "។



# យុទ្ធសាស្ត្រ ថ្មីសំរាប់ ឆ្នាំ ២០០៦

## សន្តិភាព និង យុត្តិធម៌

- ប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាលើកុមារ
- ចូលរួមលុបបំបាត់ពលកម្មកុមារដែលមានទំរង់ធ្ងន់ធ្ងរ និងគ្រោះថ្នាក់បំផុត
- កែប្រែភាពធ្លាក់ចុះនៃសីលធម៌ គុណតំលៃគ្រួសារ និងស្មារតីសាមគ្គីភាព
- ប្រឆាំងនឹងការរំលោភអំណាច និងការបដិសេធន៍ដែលធ្វើអោយរងទុក្ខដល់ជនក្រីក្រ និងជនដែលងាយរងគ្រោះ ។

## សន្តិសុខស្បៀង និង ទឹក

- ផ្តល់លទ្ធភាពដើម្បីអោយមានទឹកស្អាតគ្រប់គ្រាន់
- អភិវឌ្ឍផលិតភាពកសិកម្ម
- បង្កើនលទ្ធភាពអាហាររូបត្ថម្ភ
- កាត់បន្ថយភាពងាយរងគ្រោះលើសេដ្ឋកិច្ច
- ស្តាបនាគ្រឹះស្ថានអប់រំសាធារណៈ និងធនធានសាធារណៈ
- សំរេចការគ្រប់គ្រងធនធានកំររបស់សហគមន៍អោយបានស្ថិតស្ថេរ ។

## មេរោគអេដស៍ និង ជំងឺអេដស៍

- ធ្វើវិភាគទានដើម្បីលុបបំបាត់ស្លាកស្នាមទុរយស និងការរើសអើងនៃ PLHA និង OVC
- ធ្វើវិនិយោគលើធនធាន រចនាសម្ព័ន្ធ ប្រព័ន្ធនានា ដែលអភិវឌ្ឍសមត្ថភាពរបស់គ្រួសារ និងសហគមន៍ដើម្បីការពារ ដោះស្រាយ សម្រាល និងឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍
- ប្តេជ្ញាចំពោះចំលើយដែលមានលក្ខណៈកែប្រែអាណិតអាសូរ និងបត់បែន ដើម្បីឆ្លើយតបទៅនឹងមេរោគអេដស៍និងជំងឺអេដស៍ក្នុងបំណងពង្រឹងសហគមន៍
- ស្វែងរកភាពជាដៃគូជាមួយនឹងរដ្ឋាភិបាល និងអង្គការនានា ដែលធ្វើអោយផ្លែផ្កា និងប្រសិទ្ធភាពឈានដល់កំរិតអតិបរមានៅក្នុងសហគមន៍ដែលយើងធ្វើការជាមួយ ។

## សុខភាព និង អាហាររូបត្ថម្ភ

- ស្វែងរកយុទ្ធសាស្ត្រនានា ដែលធ្វើអោយអាហាររូបត្ថម្ភកាន់តែប្រសើរឡើង និងអភិវឌ្ឍសុខភាពបឋមរបស់កុមារ និងមាតានៅក្នុងតំបន់គោលដៅរបស់ World Vision Cambodia
- ធ្វើវិភាគទានដើម្បីកាត់បន្ថយការស្លាប់របស់កុមារពីមេរោគដែលអាចបង្ការបាន ដូចជា រោគរលាកសួត និង រាគរូស។

## ការអប់រំ

- អភិវឌ្ឍការខិតអោយជិតទៅដល់ការអប់រំ
- ធ្វើការសម្របសម្រួលជាមួយភ្នាក់ងាររដ្ឋាភិបាល និងក្រៅរដ្ឋាភិបាលដើម្បីធានាអោយបានថា ១00% នៃកុមារក្នុងតំបន់ World Vision ពិតជាបានបញ្ចប់សាលាបឋមសិក្សា
- ពិនិត្យរនាំងសង្គម និងសេដ្ឋកិច្ចដែលរារាំងជនក្រីក្រ ជាពិសេសយុវតី និងយុវតីពិការ មិនអោយទទួលបានការអប់រំ។






ចំណាយរបស់អង្គការទស្សនៈពិភពលោកកម្ពុជា
តាមផ្នែកនិមួយៗ

# របាយការណ៍ហិរញ្ញវត្ថុសង្ខេប

## សំរាប់អង្គការទស្សនៈពិភពលោកកម្ពុជា

ប្រាក់ចំណូលរបស់អង្គការទស្សនៈពិភពលោកកម្ពុជាក្នុងឆ្នាំសារពើពន្ធ២០០៥ (ខែតុលា ឆ្នាំ ២០០៤ ដល់ខែ កញ្ញា ឆ្នាំ ២០០៥) មានចំនួន ១៦.៧២៣.៣៧១ ដុល្លារអាមេរិក ។ ចំនួននេះរួមមាន ២.០២៧.១៣២ ដុល្លារអាមេរិក ជាវិភាគទានដែលមិនមែនជាសាច់ប្រាក់ ដូចជាជំនួយស្បៀងអាហារជាដើម ។ ចំណាយសរុបនៅឆ្នាំសារពើពន្ធ ២០០៥ គឺ ១៤.៨៩១.២០០ ដុល្លារអាមេរិក ដែល ៦% ត្រូវបានចំណាយលើការគ្រប់គ្រងយុទ្ធសាស្ត្រ (ចំណាយផ្សេងៗ) ។

**យើងសូមថ្លែងអំណរគុណដល់ម្ចាស់ជំនួយនៅក្នុងឆ្នាំ ២០០៥ ទាំងអស់ ដូចខាងក្រោមនេះ :**

**ការិយាល័យផ្គត់ផ្គង់របស់អង្គការទស្សនៈពិភពលោក**

អូស្ត្រាលី ១៩% កម្ពុជា ៣% កាណាដា ១៦% អាល្លឺម៉ង់ ២% ហុងកុង ១១% ជប៉ុន ២% ម៉ាឡេស៊ី ១% ហូឡង់ ណូវែលសឺឡង់ ១០% សឹង្ហបុរី ១% ស្វីស ១% ចក្រភពអង់គ្លេស ១០% និងសហរដ្ឋអាមេរិក ២៤%

**ម្ចាស់ជំនួយ**

ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី (AusAID) • ស្ថានទូតអូស្ត្រាលី • មូលនិធិសិក្សាស្រាវជ្រាវកសិកម្មកម្ពុជា (CARF) • ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិកាណាដា (CIDA) • ស្ថានទូតជប៉ុន • អង្គការសម្ព័ន្ធភាពខ្មែរប្រយុទ្ធនឹងជំងឺអេដស៍ (KHANA) • កម្មវិធីស្បៀងអាហារពិភពលោក(WFP) • ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិសហរដ្ឋអាមេរិក (USAID) • University Research Co., LLC (URC) • ក្រសួងការបរទេសសហរដ្ឋអាមេរិក • ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិណូវែលសឺឡង់ (NZAID) • ក្រសួងអន្តរជាតិសំរាប់ការអភិវឌ្ឍន៍ចក្រភពអង់គ្លេស (DFiD)

# របាយការណ៍ហិរញ្ញវត្ថុសង្ខេប

## សំរាប់វីសិនហ្វាន់កម្ពុជា

វីសិនហ្វាន់កម្ពុជា (VFC) គឺជាស្ថាប័នមីក្រូហិរញ្ញវត្ថុដាច់ដោយឡែក ជាកម្មសិទ្ធិរបស់អង្គការទស្សនៈពិភពលោកកម្ពុជា ។ ឆ្នាំសារពើពន្ធរបស់វីសិនហ្វាន់កម្ពុជាស្របគ្នានឹងឆ្នាំប្រតិទិនដែរ ។ នៅដំណាច់ខែធ្នូ ឆ្នាំ ២០០៥ ដើមទុនរបស់វីសិនហ្វាន់កម្ពុជា បានកើនឡើងដល់ ២.៩៤៥.២៨៥ ដុល្លារអាមេរិក ។

ការលូតលាស់ផលប័ត្រកម្ចីជាដុល្លារសហរដ្ឋអាមេរិក
១២០% កំណើន







មូលនិធិដែលបានពីការិយាល័យផ្ដល់ជំនួយ/
អ្នកផ្ដល់ជំនួយរបស់ វីសិនហ្វាន់កម្ពុជា

# តំលៃស្នូលរបស់យើង

## ១
### យើងជាគ្រីស្ទបរិស័ទ

យើងបានទទួលការត្រាស់ហៅឱ្យបំរើអ្នកដទៃក្នុងភាពបរិបូរណ៍នៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ ។

## ២
### យើងប្តេជ្ញាជួយដល់ជនក្រីក្រ

យើងត្រូវត្រាស់ហៅឱ្យសំរាលតំរូវការ និងទុក្ខវេទនា ភ្ជាប់ទំនាក់ទំនងរវាងអ្នកក្រ និងអ្នកមាន ។

## ៣
### យើងគោរពតំលៃមនុស្ស

យើងចាត់ទុកមនុស្សទាំងអស់ថាត្រូវបានបង្កើត និងស្រលាញ់ដោយព្រះជាម្ចាស់ ដោយម្នាក់ៗមានលក្ខណៈពិសេស ទទួលសេចក្តីថ្លៃថ្នូរ ការគោរព និងមានតំលៃក្នុងខ្លួន ។

## ៤
### យើងជាអ្នកបំរើដែលមានការទទួលខុសត្រូវខ្ពស់

យើងស្មោះត្រង់ចំពោះគោលបំណងនៃធនធានដែលយើងបានទទួល និងគ្រប់គ្រងធនធានទាំងនោះក្នុងរបៀបដែលនាំមកនូវផលប្រយោជន៍ជាអតិបរិមាដល់ជនក្រីក្រ ។

## ៥
### យើងជាដៃគូ

ក្នុងនាមជាសមាជិកនៃអង្គការទស្សនៈពិភពលោកអន្តរជាតិ យើងព្រមទទួលយកកាតព្វកិច្ចដែលមានការចូលរួមគោលដៅរួម និងមានគណនេយ្យភាពទៅវិញទៅមក ។

## ៦
### យើងជាអ្នកឆ្លើយតប

យើងឆ្លើយតបចំពោះគ្រោះអាសន្នដែលគំរាមកំហែងដល់អាយុជីវិត ព្រមទាំងស្ថានភាពសេដ្ឋកិច្ចសង្គមស្មុគស្មាញដែលតំរូវអោយមានការអភិវឌ្ឍន៍យូរអង្វែង ។

**អត្ថបទ និង ថតរូបដោយៈ**
ក្រុមតស៊ូមតិ និងទំនាក់ទំនង
ក្រុមសម្របសម្រួលផ្នែកទីផ្សារ និងរកមូលនិធិរបស់វីសិនហ្វាន់កម្ពុជា
រ៉ូវេណា គ្រុស

**រចនាក្រាហ្វិក និងកាច់ទំព័រដោយៈ**
ណូវ៉ាឌីហ្សាញ
novadesign@citylink.com.kh

**បោះពុម្ពផ្សាយនៅកម្ពុជាក្នុងឆ្នាំ ២០០៦**
ផ្នែកនៃព័ត៌មាននេះអាចនឹងបោះពុម្ពផ្សាយបន្ត ប្រសិនបើមានការអនុញ្ញាត ។
របាយការណ៍នេះអាចរកបានពីអង្គការទស្សនៈពិភពលោកកម្ពុជា។

World Vision

**អង្គការទស្សនៈពិភពលោកកម្ពុជា**

អគារលេខ ២០ ផ្លូវលេខ ៧១
ទន្លេបាសាក់ ចំការមន
ប្រអប់សំបុត្រលេខ ៤៧៩
ភ្នំពេញ - កម្ពុជា

ទូរស័ព្ទ: +៨៥៥ - ២៣ - ២១៦០៥២
ទូរសារ: +៨៥៥ - ២៣ - ២១៦២២០

អ៊ីម៉ែល: Cambodia@wvi.org
www.worldvision.org.kh

